**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាលដែលសរសេរជាអក្សរកាត់ថា គ.ជ.ប.ប.។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅលើកកម្ពស់និងជំរុញការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សង្គមសេដ្ឋកិច្ច។



**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមាសភាព តួនាទី និងភារកិច្ចនៃ គ.ជ.ប.ប.

**មាត្រា៤ .-**

គ.ជ.ប.ប. មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១រូប | អនុប្រធាន |
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១រូប | អនុប្រធាន |
| - តំណាងសភាមុខរបរនិងមីក្រូសហគ្រាស | ១រូប | អនុប្រធាន |
| - តំណាងនិយោជក | ១រូប | អនុប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| - តំណាងក្រសួងផែនការ | ១រូប | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ១រូប | សមាជិក |
| - តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | ១រូប | សមាជិក |
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២រូប | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល | ១រូប | សមាជិក |
| - តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប | សមាជិក |
| - តំណាងក្រសួងធនធានទឹកនិងឧតុនិយម | ១រូប | សមាជិក |
| - តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ១រូប | សមាជិក |
| - តំណាងក្រសួងបរិស្ថាន | ១រូប | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| - តំណាងក្រសួងរ៉ែនិងថាមពល | ១រូប | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | សមាជិក |
| - តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ១រូប | សមាជិក |
| - តំណាងក្រសួងកិច្ចការនារី | ១រូប | សមាជិក |
| - តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១រូប | សមាជិក |
| - តំណាងទីភ្នាក់ងារជាតិមុខរបរនិងការងារ | ១រូប | សមាជិក |
| - តំណាងសភាពាណិជ្ជកម្ម | ១រូប | សមាជិក |
| - តំណាងនិយោជក | ៤រូប | សមាជិក |
| - តំណាងនិយោជិត | ៤រូប | សមាជិក |

| | | |
|---|---|---|
| - តំណាងអ្នកផ្តល់ការបណ្តុះបណ្តាល | ៣រូប | សមាជិក |
| - តំណាងអង្គការអន្តរជាតិខាងការងារ | ១រូប | សមាជិក |
| - តំណាងវិទ្យាស្ថានដើម្បីភាពញញឹមនៃកុមារ | ១រូប | សមាជិក |
| - តំណាងសមាគមសណ្ឋាគារកម្ពុជា | ១រូប | សមាជិក |
| - តំណាងទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ | ១រូប | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃ គ.ជ.ប.ប. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

គ.ជ.ប.ប. មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយនិងគម្រោងផែនការជាតិសម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- សម្របសម្រួលនិងតម្រង់ទិសការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សង្គមសេដ្ឋកិច្ច
- លើកគម្រោងកែទម្រង់និងអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឱ្យក្លាយជាប្រព័ន្ធមួយដែលមានគុណភាពនិងប្រសិទ្ធភាពខ្ពស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម កសិកម្ម សេវាកម្ម ផ្សារភ្ជាប់ទៅនឹងអាទិភាពនៃការអភិវឌ្ឍជាតិនិងមានទំនាក់ទំនងរវាងកន្លែងធ្វើការងារនិងគ្រឹះស្ថានបណ្តុះបណ្តាល។

**មាត្រា៦ .-**

គ.ជ.ប.ប. ត្រូវបង្កើតគណៈកម្មាធិការបណ្តុះបណ្តាលរាជធានី ខេត្ត ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ជ.ប.ប.។

## ជំពូកទី៣

## សមាសភាព តួនាទី និងភារកិច្ចនៃគណៈកម្មការប្រតិបត្តិ

**មាត្រា៧ .-**

គ.ជ.ប.ប. ត្រូវជ្រើសតាំងសមាជិករបស់ខ្លួន៩(ប្រាំបួន)រូប ធ្វើជាគណៈកម្មការប្រតិបត្តិ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | អនុប្រធាន |
| - តំណាងក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាល | ២រូប | សមាជិក |
| - តំណាងនិយោជក | ២រូប | សមាជិក |
| - តំណាងនិយោជិត | ២រូប | សមាជិក |
| - តំណាងអ្នកផ្តល់ការបណ្តុះបណ្តាល | ១រូប | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មការប្រតិបត្តិនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ជ.ប.ប.។



**មាត្រា៨ .-**

គណៈកម្មការប្រតិបត្តិនេះមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងក្នុងនាម គ.ជ.ប.ប. នូវមូលនិធិជាតិបណ្តុះបណ្តាល
- រៀបចំកម្មវិធីនិងរបៀបវារៈនៃកិច្ចប្រជុំរបស់ គ.ជ.ប.ប.
- លើកសំណើដែលពាក់ព័ន្ធដល់ការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈជូន គ.ជ.ប.ប. ពិនិត្យនិងសម្រេច។

## ជំពូកទី៤

## ការប្រព្រឹត្តទៅនៃ គ.ជ.ប.ប.

**មាត្រា៩ .-**

គ.ជ.ប.ប. ត្រូវធ្វើការប្រជុំយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ គ.ជ.ប.ប. អាចកោះប្រជុំវិសាមញ្ញ។

គ.ជ.ប.ប. អាចអញ្ជើញអ្នកជំនាញបច្ចេកទេសជាតិនិងអន្តរជាតិចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា១០ .-**

គ.ជ.ប.ប. អាចមានទីប្រឹក្សាបច្ចេកទេសដែលជាអ្នកជំនាញការជាតិនិងអន្តរជាតិមានសមត្ថភាពជំនាញនិងបទពិសោធន៍សម្រាប់ជួយបំពេញការងារ។

**មាត្រា១១ .-**

គ.ជ.ប.ប. មានសិទ្ធិបង្កើតគណៈកម្មការនិងក្រុមការងារជំនាញមួយចំនួនសម្រាប់ជួយជំរុញការងារអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

សមាសភាពនិងតួនាទីភារកិច្ចរបស់គណៈកម្មការនិងក្រុមការងារជំនាញនីមួយៗត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ជ.ប.ប.។

**មាត្រា១២ .-**

គ.ជ.ប.ប. និងគណៈកម្មការប្រតិបត្តិមានអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈជាលេខាធិការដ្ឋាន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ជ.ប.ប.។

**មាត្រា១៣ .-**

គ.ជ.ប.ប. មានសិទ្ធិប្រើត្រារបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

## ជំពូកទី៥

## ប្រភពធនធាននៃ គ.ជ.ប.ប.

**មាត្រា១៤ .-**

គ.ជ.ប.ប. មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិដែលដាក់បញ្ចូលថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១៥.-**

គ.ជ.ប.ប. មានសិទ្ធិទទួល គ្រប់គ្រង និងចាត់ចែងប្រើប្រាស់នូវមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀតតាមនីតិវិធីច្បាប់ជាធរមាន សម្រាប់អនុវត្តសកម្មភាពតាមការចាំបាច់របស់ខ្លួន។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៦.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការបង្កើតអង្គភាពនានាចំណុះ គ.ជ.ប.ប. ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមអនុក្រឹត្យនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៧.-**

- អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- អនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- អនុក្រឹត្យលេខ៧៩០ អនក្រ.តត ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- អនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលមាត្រា២នៃអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- អនុក្រឹត្យលេខ១០៦៦ អនក្រ.តត ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- អនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា២ថ្មីនៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលមាត្រា២នៃអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- អនុក្រឹត្យលេខ១០៣ អនក្រ.តត ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- អនុក្រឹត្យលេខ២០៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ថ្មី(ពីរ) នៃអនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា២ថ្មីនៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលមាត្រា២នៃអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- អនុក្រឹត្យលេខ១៣៥៩ អនក្រ.តត ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល



- អនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- អនុក្រឹត្យលេខ៩០៩ អនក្រ.តត ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- អនុក្រឹត្យលេខ១៣២១ អនក្រ.តត ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិបណ្តុះបណ្តាល និង

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមីនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ